ឯកសារទស្សនាទាន: សិក្ខាសាលាថ្នាក់តំបន់ដើម្បីគាំទ្រការផ្លាស់ប្តូរចំណេះដឹង
និងបទពិសោធន៍គ្នាស្តីពីការប្រតិបត្តិមណ្ឌលស្នាក់នៅនៅក្នុងរដ្ឋជាសមាជិកអាស៊ាន”

**ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១ បាងកក ថៃឡង់ដ៍**

សាវតារ

អនុលោមតាមក្របខ័ណ្ឌអន្តរជាតិស្តីពីការជួញដូរមនុស្ស អនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រីនិងកុមារ (ACTIP) កំណត់យ៉ាងច្បាស់នូវការប្តេជ្ញារួមរបស់រដ្ឋជាសមាជិកអាស៊ានចំពោះអភិក្រមផ្អែកលើសិទ្ធិ និងផ្តោតលើជនរងគ្រោះចំពោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ប៉ុន្តែ នៅក្នុងប្រទេសជាច្រើននៅជុំវិញពិភពលោក រួមទាំងនៅក្នុងតំបន់អាស៊ាន ជនរងគ្រោះដោយការជួញដូរមនុស្ស ជាញឹកញាប់ ត្រូវបានដាក់ឲ្យស្នាក់នៅក្នុងមណ្ឌលស្នាក់នៅបិទជិត ដោយមិនមានការយល់ព្រមរបស់ពួកគេ ប្រឆាំងនឹងឧត្តមប្រយោជន៍របស់ពួកគេ ហើយជួនកាល តាមវិធីនានាដែលផ្ទុយនឹងសិទ្ធិរបស់ពួកគេ។ ក្នុងបរិបទនេះ កម្មវិធី ASEAN-ACT បានធ្វើការសិក្សាអំពីច្បាប់ គោលនយោបាយ និងការប្រតិបត្តិស្តីពីមណ្ឌលស្នាក់នៅនៅក្នុងតំបន់អាស៊ានក្នុងឆ្នាំ ២០១៨។

អំណះអំណាងដែលបានរកឃើញសម្រាប់ការប្រើមណ្ឌលស្នាក់នៅបិទជិត រួមមានភាពចាំបាច់ដើម្បីការពារជនរងគ្រោះពីការរងទុក្ខទោសថែមទៀត ការគេចពីជនជួញដូរ ។ល។ ដោយឡែក ក្នុងករណីដែលជនរងគ្រោះត្រូវបានចាត់ទុកថាបានសមគំនិតនៅក្នុងការជួញដូរពួកគេខ្លួនឯង ជនរងគ្រោះអាចចាត់ទុកថាចាំបាច់ត្រូវទទួល ‘ការអប់រំឡើងវិញ’ ដោយសារការពាក់ព័ន្ធរបស់ពួកគេនៅក្នុងសកម្មភាពខុសច្បាប់នានា ដូចជាពេស្យាចារ ជាដើម។ អំណះអំណាងមួយទៀត គឺទាក់ទិននឹងស្ថានភាពចំណាកស្រុកនៃជនរងគ្រោះ នៅក្នុងករណីមិនមានទិដ្ឋាការដើម្បីធ្វើឲ្យការស្នាក់នៅរបស់ពួកក្នុងប្រទេសមានភាពស្របច្បាប់។ អំណះអំណាងច្រើនទីបីសម្រាប់ការផ្តល់មណ្ឌលស្នាក់នៅឲ្យជនរងគ្រោះនៅក្នុងអគារបិទជិត គឺដើម្បីធានាឲ្យបាននូវការចូលរួមរបស់ពួកគេនៅក្នុងការស៊ើបអង្កេត និងការយកមកកាត់ទោសនូវជនជួញដូរដែលត្រូវបានគេចោទប្រកាន់។ ប៉ុន្តែ អំណះអំណាងទាំងនេះ ជាញឹកញាប់ណាស់ មិនបានបំពេញតាមគោលបំណងនៃអំណះអំណាងទាំងនេះទេ ហើយសំខាន់ជាងនេះទៅទៀត ជាញឹកជាប់ មិនអាចទទួលយកបានចំពោះការពិនិត្យពិច័យពីទស្សនៈផ្អែកលើសិទ្ធិ និងផ្តោតលើជនរងគ្រោះឡើយ។ អភិក្រមផ្អែកលើសិទ្ធិចំពោះកិច្ចការពារនិងការជួយជនរងគ្រោះ អនុលោមតាមកាតព្វកិច្ចរបស់រដ្ឋដែលមានចែងនៅក្នុងអនុសញ្ញា ACTIP និងនៅក្នុង

+66 2 2๕๙ ๔๓๑๑
@ info@aseanact.org
No.๑ Glas Haus Building, Office ๘๐๑, ๘th Floor, Sukhumvit 2๕, Klongtoey-Nua, Wattana, Bangkok ๑๐๑๑๐ Thailand
ASEAN-ACT is supported by the Australian Government and implemented by Cardno

ច្បាប់អន្តរជាតិ គឺមានសារៈសំខាន់ចំពោះការស្តារនីតិសម្បទានិងការធ្វើសមាហរណកម្មជនរងគ្រោះ ក៏ដូចជាចំពោះការពង្រឹងចម្លើយតបនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចំពោះការជួញដូរមនុស្ស។

កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT) ដោយសហការជាមួយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស (MSDHS) នៃប្រទេសថៃ ក្នុងឋានៈជាស្ថាប័នទំនាក់ទំនងនៃកិច្ចប្រជុំឧត្តមមន្ត្រីស្តីពីការងារសង្គមកិច្ច និងអភិវឌ្ឍន៍ (SOMSWD), តំណាងប្រទេសថៃសម្រាប់សិទ្ធិកុមារនៅក្នុងគណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) និង រដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន ជាអ្នកដឹកនាំស្ម័គ្រចិត្តលើការងារប្រឆាំងការជួញដូរមនុស្សសម្រាប់ក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខ័ណ្ឌអាស៊ាន (SOMTC) កំពុងរៀបចំសិក្ខាសាលាថ្នាក់តំបន់មួយដើម្បីបង្ហាញរបកគំហើញសំខាន់ៗនៃការសិក្សារបស់កម្មវិធី សំដៅជំរុញការពិភាក្សា និងការផ្លាស់ប្តូរចំណេះដឹងនិងបទពិសោធន៍គ្នាអំពីការប្រតិបត្តិមណ្ឌលស្នាក់នៅ នៅក្នុងរដ្ឋជាសមាជិកអាស៊ាន ជាពិសេសនៅក្នុងអំឡុងពេលមានការរាលដាលមេរោគកូវីដ-១៩។

## គោលបំណងនៃសិក្ខាសាលា

សិក្ខាសាលា នឹង៖

- បង្ហាញរបកគំហើញសំខាន់ៗពីការសិក្សា និងផ្តល់អនុសាសន៍ទាក់ទិននឹងច្បាប់ គោលនយោបាយ និងការប្រតិបត្តិសម្រាប់ពិចារណា។
- ផ្តល់ជូនវេទិកាមួយសម្រាប់ពិភាក្សាការវិវត្តនិងបញ្ហាប្រឈមនានានៅក្នុងការគាំទ្រជនរងគ្រោះ។
- ពង្រឹងការយល់ដឹង និងចែករំលែកការប្រតិបត្តិល្អនៅក្នុងអភិក្រមផ្អែកលើសិទ្ធិ និងផ្តោតលើជនរងគ្រោះ។
- គាំទ្រដល់កិច្ចប្រឹងប្រែងបច្ចុប្បន្នរបស់រដ្ឋជាសមាជិកអាស៊ានក្នុងការជំរុញសេរីភាពក្នុងការបំលាស់ទី និងការមិនធ្វើទណ្ឌកម្មលើជនរងគ្រោះដោយការជួញដូរ។

## អ្នកចូលរួម

សិក្ខាសាលានេះ បើកទូលាយជូនស្ថាប័នរដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ានដែលទទួលបន្ទុកលើការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រួមមានសមាជិកនៃគណៈកម្មាធិការ/ក្រុមការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេស អ្នកដែលពាក់ព័ន្ធក្នុងការងាររដ្ឋបាលនិងការគ្រប់គ្រងមណ្ឌលស្នាក់នៅ/អាគារស្នាក់នៅ/ជម្រកបណ្តោះអាសន្ន/ជម្រកសហគមន៍ ។ល។ សម្រាប់ជនរងគ្រោះដោយការជួញដូរមនស្ស នាយកដ្ឋាន

អន្តោប្រវេសន៍ និងតំណាងផ្នែកអាស៊ាននានា ដូចជា SOMTC, SOMSWD, គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស (AICHR) និងគណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC)។

សិក្ខាសាលា នឹងប្រព្រឹត្តទៅដោយប្រើភាសាអង់គ្លេស ដោយមានការបកប្រែប្រដេញជាភាសារបស់រដ្ឋជាសមាជិកអាស៊ានទាំងអស់ (បាហាសាឥណ្ឌូណេស៊ី ភូមា ខ្មែរ ឡាវ ថៃ និងវៀតណាម)។

ព័ត៌មានលម្អិតអំពីសិក្ខាសាលា

| | |
|---|---|
| កាលបរិច្ឆេទ: | ២៧ មេសា ២០២១ |
| ម៉ោង: | ០៨.៣០ -១២.៣០ រសៀល (ម៉ោងនៅបាងកក) |
| ប្រភេទសិក្ខាសាលា | សិក្ខាសាលាថ្នាក់តំបន់ |
| ទម្រង់: | ទម្រង់ចម្រុះ ត្រូវបានស្នើឡើង ដែលនៅក្នុងនោះ អ្នកចូលរួមខ្លះនឹងចូលរួមសិក្ខាសាលាផ្ទាល់នៅបាងកក ខណៈដែលអ្នកដែលមិនអាចធ្វើដំណើរទៅបាងកកបាន នឹងចូលរួមតាមអនឡាញ (Zoom) |
| អ្នករៀបចំ: | កម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស (ASEAN-ACT)<br>ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស (MSDHS)<br>កិច្ចប្រជុំឧត្តមមន្ត្រីស្តីពីការងារសង្គមកិច្ច និងអភិវឌ្ឍន៍ (SOMSWD) ប្រទេសថៃ<br>ក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខ័ណ្ឌអាស៊ាន (SOMTC)<br>សាធារណរដ្ឋហ្វីលីពីន |

របៀបវារៈព្រាង

| ម៉ោង | របៀបវារៈ | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:៣០ | ចុះឈ្មោះ | ASEAN-ACT *(in person and via zoom)* |
| ០៩.០០ | សុន្ទរកថាស្វាគមន៍ | តំណាងនៃក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី (DFAT)<br><br>ឯកឧត្តម Hon. Bernardo C. Florece Jr., អនុរដ្ឋមន្ត្រីទទួលបន្ទុកការងារសន្តិភាព និងសណ្តាប់ធ្នាប់ ក្រសួងមហាផ្ទៃនិងរដ្ឋាភិបាលមូលដ្ឋាន សាធារណរដ្ឋហ្វីលីពីន / ប្រធានស្ម័គ្រចិត្តផ្នែកប្រឆាំងការជួញដូរមនុស្សនៃក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខ័ណ្ឌអាស៊ាន (SOMTC) |
| | សុន្ទរកថាបើក | លោកស្រី Patcharee Arayakul, លេខាធិការអចិន្ត្រៃយ៍ ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស (MSDHS) នៃប្រទេសថៃ ក្នុងឋានៈជាស្ថាប័នទំនាក់ទំនងនៃកិច្ចប្រជុំឧត្តមមន្ត្រីស្តីពីការងារសង្គមកិច្ច និងអភិវឌ្ឍន៍ (SOMSWD) ប្រទេសថៃ |
| ០៩:៣០ | បទបង្ហាញស្តីពីរបកគំហើញបឋមនៃការសិក្សាឆ្នាំ ២០១៨ ស្តីពីការប្រតិបត្តិមណ្ឌលស្នាក់នៅ<br><br>សំណួរ និងចម្លើយ | បណ្ឌិត Marika McAdam, អ្នកពិគ្រោះការកម្មវិធី ASEAN-ACT និងជាអ្នកនិពន្ធឯកសារសិក្សា<br><br>*អ្នកសម្របសម្រួល:* Nurul Qoiriah, នាយកផ្នែកបរិយាប័ន្ន និងសិទ្ធិជនរងគ្រោះ |
| ១០:៣០ | សម្រាកពិសាអាហារសម្រន់ | សម្រាក ១៥ នាទី (សម្រាប់អ្នកចូលរួមផ្ទាល់ និងអ្នកចូលរួមតាម zoom) |
| ១០:៤៥ | ការពិភាក្សាក្រុមអ្នកជំនាញ: ចែករំលែកការរៀនសូត្រនិងបញ្ហាប្រឈម ការប្រតិបត្តិល្អ និងការកែ | ប្រតិភូពីថៃ (បញ្ជាក់ជូននៅពេលក្រោយ)<br>ប្រតិភូពីម៉ាឡេស៊ី (បញ្ជាក់ជូននៅពេលក្រោយ)<br>ប្រតិភូពីហ្វីលីពីន (បញ្ជាក់ជូននៅពេលក្រោយ) |

| ម៉ោង | របៀបវារៈ | អ្នកសម្របសម្រួល |
|---|---|---|
| | លម្អការប្រតិបត្តិមណ្ឌលស្នាក់នៅ នៅមុនពេលនិងក្នុងអំឡុងពេលមានវិបត្តិកូវីដ-១៩ | ប្រតិភូពីឥណ្ឌូណេស៊ី (បញ្ជាក់ជូននៅពេលក្រោយ)<br>ប្រតិភូពីកម្ពុជា (បញ្ជាក់ជូននៅពេលក្រោយ) |
| | *សំណួរ និងចម្លើយ* | *អ្នកសម្របសម្រួល:* Archemides Siguan, នាយកកម្មវិធីអាស៊ានសម្រាប់កម្មវិធី ASEAN-ACT |
| ១១.៤៥ | វេទិកាបើកទូលាយ - ការពិភាក្សាអំពីទិសដៅខាងមុខ: មតិយោបល់ និងអនុសាសន៍ដើម្បីកែលម្អ និងដោះស្រាយបញ្ហាប្រឈម/គម្លាត | *អ្នកសម្របសម្រួល:* Archemides Siguan, នាយកកម្មវិធីអាស៊ានសម្រាប់កម្មវិធី ASEAN-ACT |
| ១២.២០ | សុន្ទរកថាបិទ | ឯកឧត្តម Wanchai Roujanavong, តំណាងប្រទេសថៃប្រចាំគណៈកម្មការអាស៊ានទទួលបន្ទុកលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) |
| ១២:៣០ | អាហារថ្ងៃត្រង់ | អ្នកចូលរួមផ្ទាល់ (បាងកក) |